សម្ព័ន្ធខ្មែរជំរឿន
និងការពារសិទ្ធិមនុស្ស
លីកាដូ

LICADHO

Cambodian League for the Promotion and Defense of Human Rights














# ស្ត្រីរួមគ្នាដើម្បីសិទ្ធិការងារ

## រឿងរ៉ាវនៃការតស៊ូចំនួន៦


របាយការណ៍សង្ខេបចេញផ្សាយ
ខែវិច្ឆិកា ឆ្នាំ២០២២

# ស្ត្រីរួមគ្នាដើម្បីសិទ្ធិការងារ:

## រឿងរ៉ាវនៃការតស៊ូចំនួន ៦

របាយការណ៍សង្ខេបចេញផ្សាយខែវិច្ឆិកា ឆ្នាំ២០២២


**សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ**

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

# សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស
# (លីកាដូ)

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា។ ចាប់តាំងពីអង្គការលីកាដូ ត្រូវបានបង្កើត ឡើងនៅឆ្នាំ១៩៩២ អង្គការនេះ គឺជាអង្គការដែលស្ថិតនៅជួរមុខគេ ក្នុងកិច្ចការពារសិទ្ធិពលរដ្ឋ សិទ្ធិ នយោបាយ សិទ្ធិសេដ្ឋកិច្ច និងសិទ្ធិសង្គមរបស់ប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជា និងលើកកម្ពស់ ការគោរពសិទ្ធិទាំងនេះពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា និងអង្គការនានា។ ដោយបានកសាងនូវ សមិទ្ធិផលល្អក្នុងអតីតកាល លីកាដូបានបន្តដើរតួនាទីជាអ្នកតស៊ូមតិសម្រាប់ប្រជាពលរដ្ឋ និងធ្វើការឃ្លាំមើលស្ថានភាពសង្គមតាមរយៈកម្មវិធីឃ្លាំមើល និងការពារសិទ្ធិមនុស្ស ពីការិយាល័យកណ្តាលរបស់ខ្លួននៅរាជធានីភ្នំពេញ និងនៅតាមសាខាទាំង ១២ ខេត្តផ្សេងទៀត។

**កម្មវិធីឃ្លាំមើល និងការពារសិទ្ធិមនុស្ស**

**កម្មវិធីលើកកម្ពស់ និងការទាក់ទាញមតិគាំទ្រ**

### ឃ្លាំមើលការរំលោភសិទ្ធិមនុស្ស សិទ្ធិស្ត្រី និងសិទ្ធិកុមារ

បុគ្គលិកអង្គការលីកាដូ ធ្វើការឃ្លាំមើល និងស្រាវជ្រាវលើករណីរំលោភសិទ្ធិមនុស្ស ករណីរំលោភបំពានលើស្ត្រី និងកុមារ ហើយជនរងគ្រោះ ត្រូវបានផ្តល់សេវាជួយជ្រោមជ្រែង តាមរយៈការធ្វើអន្តរាគមន៍ជាមួយអាជ្ញាធរមូលដ្ឋាន និងមន្ត្រីតុលាការ។

### ជំនួយផ្នែកសេវាសុខភាព និងសេវាកម្មសង្គមកិច្ច

ក្រុមគ្រូពេទ្យផ្តល់សេវាសុខភាពដល់ជនជាប់ឃុំ និងមន្ត្រីពន្ធនាគារនៅជនបទ និងទីក្រុង ជនរងគ្រោះពីការរំលោភសិទ្ធិមនុស្ស និងគ្រួសារ ដែលស្ថិតនៅតំបន់តាំងទីលំនៅថ្មី។ ក្រុមការងារសេវាសង្គមធ្វើការវាយតម្លៃពីតម្រូវការរបស់ជនរងគ្រោះ និងក្រុមគ្រួសារ របស់អ្នកទាំងនោះ ហើយផ្តល់ជំនួយ សម្ភារៈ និងម្ហូបអាហារ រយៈពេលខ្លី។

### ការប្រឹក្សាផ្នែកច្បាប់ដល់ជនជាប់ឃុំ

អ្នកប្រឹក្សាផ្នែកច្បាប់ ផ្តល់ការប្រឹក្សាដល់ជនជាប់ឃុំនៅពន្ធនាគារនៅជនបទ និងទីក្រុង ដើម្បីធ្វើឲ្យប្រាកដថា ជនជាប់ឃុំទាំងនោះ មានតំណាង ផ្នែកច្បាប់ នៅគ្រប់ដំណាក់កាលនៃនីតិវិធីដែលពាក់ព័ន្ធ។

### ការពិគ្រោះយោបល់ផ្នែកច្បាប់

ជនរងគ្រោះ ត្រូវបានផ្តល់ជូននូវការពិគ្រោះយោបល់ផ្នែកច្បាប់ ហើយចំពោះ ករណីសំខាន់ៗទទួលបាននូវកិច្ចការពារផ្នែកច្បាប់ ដែលផ្តល់ជូន ដោយក្រុមប្រឹក្សាផ្នែកច្បាប់ និងក្រុមមេធាវីការពារសិទ្ធិមនុស្ស។

### គាំទ្រសហជីព ក្រុមពលរដ្ឋមូលដ្ឋាន និង បណ្តាញនានា

ជួយដល់សហជីព ក្រុមពលរដ្ឋមូលដ្ឋាន និងសហគមន៍ ដែលរងគ្រោះ ដោយផ្តល់នូវកិច្ចការពារសេវាកម្មផ្នែកច្បាប់ និងសេវាសុខភាព ព្រមទាំងជួយពង្រឹងសមត្ថភាពរបស់អ្នកទាំងនោះក្នុងការតស៊ូមតិ។

### ទាក់ទាញមតិគាំទ្រជាសាធារណៈ និងតាមសហគមន៍

ករណីរំលោភសិទ្ធិមនុស្ស ដែលអង្គការលីកាដូបានឃ្លាំមើល និងស្រាវជ្រាវ ត្រូវបានចងក្រងទុកនៅក្នុងប្រព័ន្ធផ្ទុកទិន្នន័យ ដើម្បីឲ្យមានភាពងាយស្រួលក្នុងការស្វែងរកព័ត៌មានវិភាគផលិត ជារបាយការណ៍ (ការបោះពុម្ពជារបាយការណ៍ និងរបាយការណ៍សោតទស្សន៍) និងសម្រាប់ធ្វើការតស៊ូមតិផ្សេងៗទៀត។

## សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក ប្រធានអង្គការសិទ្ធិមនុស្ស លីកាដូ
ផ្ទះលេខ ១៦ ផ្លូវ៩៩ រាជធានីភ្នំពេញ កម្ពុជា
ទូរសព្ទលេខ៖ (+៨៥៥)២៣ ៧២៧ ១០២/២១៦ ៦០២

អ៊ីម៉ែល៖ licacambodia14@gmail.com
គេហទំព័រ៖ www.licadho-cambodia.org Facebook: www.facebook.com/licadho Twitter: www.twitter.com/licadho

# មាតិកា




សេចក្តីផ្តើម ទំព័រ១

កម្រងប្រវត្តិរូបរបស់សកម្មជនសហជីពជាស្ត្រី

**សារិន សុវណ្ណនី**
មន្ត្រីចងក្រងនៃសហព័ន្ធសហជីពកម្ពុជា ទំព័រ៣

**សុខ ស្រីលាភ**
បុគ្គលិកយុទ្ធនាការនៃអង្គការបណ្តាញការងារស្ត្រីរួបរួមគ្នា ទំព័រ៤

**ឃ្លាំង សុបិន្ត**
អគ្គលេខាធិការនៃសហជីពទ្រទ្រង់សិទ្ធិការងារ បុគ្គលិក កម្មករខ្មែរនៃក្រុមហ៊ុនណាហ្គាវើលដ៏ ទំព័រ៦

**អ៊ុក ឆាយ៉ារី**
ប្រធានសមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ ទំព័រ៧

**សុវណ្ណ វ៉ារី**
ប្រធានគណៈកម្មការស្ត្រីនៃសមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ទំព័រ៨

**ម៉ាក់ កាក់**
សមាជិកនៃសមាគមអ្នកធ្វើការងារតាមផ្ទះ ទំព័រ៩

# សេចក្ដីផ្ដើម




កូដករត្រូវបានអាជ្ញាធររាំងខ្ទប់ ខណៈដែលកំពុងតវ៉ានៅក្រៅកាស៊ីណូណាហ្គាវើលដ៍ ក្នុងរាជធានីភ្នំពេញ កាលពីខែធ្នូ ឆ្នាំ២០២១ ។

សកម្មជនសិទ្ធិការងារជាស្ត្រី កំពុងតែក្រោកឈរតវ៉ានឹងនិយោជកដែលកេងប្រវ័ញ្ច ក្រោកឈរឡើងដើម្បីយុត្តិធម៌ និងលក្ខខណ្ឌការងារដែលមានសុវត្ថិភាព ក៏ដូចជាតស៊ូដើម្បីបញ្ចប់អំពើហិង្សាផ្អែកលើយេនឌ័រ នៅកន្លែងធ្វើការ ។ ពួកគេកំពុងប្រឈមនឹងការគំរាមកំហែង និងការធ្វើទុក្ខបុកម្នេញពីសំណាក់និយោជក និងអាជ្ញាធរ ខណៈដែលកំពុងព្យាយាមផ្លាស់ប្ដូរផ្នត់គំនិតយេនឌ័របែបអវិជ្ជមាន និងការរំពឹងទុកនៅក្នុងសង្គម អំឡុងពេលពួកគេតស៊ូដើម្បីសិទ្ធិកម្មករនិយោជិត និងអនាគតមួយដែលស្ត្រីទាំងអស់មានសេរីភាពក្នុងការសម្ដែងមតិអំពីសិទ្ធិរបស់ពួកគេ និងអ្នកដទៃ ។

ដើម្បីប្រារព្ធយុទ្ធនាការ១៦ថ្ងៃប្រឆាំងនឹងអំពើហិង្សាផ្អែកលើយេនឌ័រក្នុងឆ្នាំ២០២២នេះ សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ (អង្គការលីកាដូ) សូមចែករំលែករឿងរ៉ាវ និងអនុសាសន៍របស់ស្ត្រីចំនួន៦នាក់ ដែលស្ថិតនៅជួរមុខនៃចលនាសិទ្ធិការងារនៅក្នុងប្រទេសកម្ពុជា ដើម្បីកោតសរសើរចំពោះការងារ និង ភាពក្លាហានរបស់ពួកគេ ។ អ្នកទាំងនេះគឺជាអ្នកដឹកនាំ និងសមាជិក សហជីព សហព័ន្ធ និងសមាគម ដែលរួមគ្នាតំណាងឱ្យកម្មករ-កម្មការិនីរោងចក្រ អ្នកប្រកបរបររកស៊ីផ្លូវភេទ កម្មករនិយោជិតផ្នែកសេវាកម្សាន្ត កម្មករនិយោជិតផ្នែកកាស៊ីណូ គ្រូបង្រៀន អ្នកបើករ៉ឺម៉កកង់បី អ្នកធ្វើការងារតាមផ្ទះ និងកម្មករដទៃផ្សេងទៀត ។

ពួកគេរួមគ្នាប្ដេជ្ញាចិត្ត ដើម្បីសិទ្ធិកម្មករ និងសម្ដែងមតិទាំងអស់គ្នាប្រឆាំងនឹងការបៀតបៀនផ្លូវភេទ និងអំពើហិង្សា ផ្អែកលើយេនឌ័រនៅកន្លែងការងារ ។ ទោះបីជាធ្វើការងារនៅវិស័យខុសៗគ្នាក្ដី ពួកគេទាំងអស់គ្នារាយការណ៍ថា សមាជិករបស់ពួកគេប្រឈមនឹងការបៀតបៀនផ្លូវភេទ ដោយជារឿយៗនិយោជក និងអាជ្ញាធរ មិនបានជួយដោះស្រាយនោះទេ ។

ភាពសកម្មនិយមនៃស្ត្រីទាំងនេះ តែងមានការលះបង់ខ្ពស់ ដោយសារពួកគេត្រូវបានបញ្ឈប់ពីការងារ ចាប់ដាក់ពន្ធនាគារ ទទួលរងអំពើហិង្សាលើរូបរាងកាយ ការតាមដាន និងការគំរាមកំហែង ។ ពួកគេបានឃើញសកម្មជនជាស្ត្រី ស៊ូទ្រាំនឹងការរិះគន់ និងការបង្អាក់ទឹកចិត្ត អំពីកត្តាយេនឌ័ររបស់ពួកគេ ពីសំណាក់សហគមន៍ អ្នករួមការងារ ឬក្រុមគ្រួសារ ។ ប៉ុន្តែពួកគេនៅតែប្ដេជ្ញាចិត្ត ដើម្បីបន្តការតស៊ូរបស់ពួកគេ ក្នុងការរួបរួមកម្មករនិយោជិត និងបញ្ចប់អំពើហិង្សាផ្អែកលើយេនឌ័រ ។




កូដករប្រមូលផ្តុំនៅក្នុងរាជធានីភ្នំពេញ កាលពីខែមករា ឆ្នាំ២០២២ ដើម្បីទាមទារឱ្យមានការទទួលយកចូលធ្វើការវិញនូវបុគ្គលិកដែលត្រូវបានបញ្ឈប់ដោយក្រុមហ៊ុនណាហ្គាវើលដ៍ ។

# សារិន សុវណ្ណនី

## មន្ត្រីចងក្រងក្នុងខេត្តកំពង់ស្ពឺ នៃសហព័ន្ធសហជីពកម្ពុជា



"បើតាមខ្ញុំគិតខ្លួនឯងប្រហែលជា ចេតនារបស់ក្រុមហ៊ុន ដោយសារតែខ្ញុំជាសកម្មជនសហជីពនៅក្នុងរោងចក្រហ្នឹង គឺសហជីពដែលឯករាជ្យ ជួយការពារសិទ្ធិនិងបញ្ហាប្រឈម របស់បងប្អូនកម្មករ"

សុវណ្ណនី ត្រូវបានបញ្ឈប់ពីការងារនៅក្នុងរោងចក្រកាត់ដេរមួយកាលពីខែមិថុនា ឆ្នាំ២០២២ ហើយនាងបាននិយាយថា នាងត្រូវបានបញ្ឈប់ពីការងារ ក្នុងពេលជាមួយកម្មករនិយោជិតជាង ១៨០នាក់ផ្សេងទៀត ដែលក្នុងនោះជាសមាជិកសហព័ន្ធសហជីពកម្ពុជាទាំងអស់ លើកលែងតែពីរនាក់ប៉ុណ្ណោះ ។ ការបញ្ឈប់កម្មករនិយោជិតទាំងនេះ ធ្វើឡើងនៅក្នុងរោងចក្រដែលមានកម្មករនិយោជិតសរុបប្រមាណជា ៣.០០០នាក់ ។

កាលពីមួយឆ្នាំមុន សុវណ្ណនី បានក្លាយជាសកម្មជនមួយរូបរបស់សហព័ន្ធសហជីព ដែលតំណាងឱ្យកម្មករនិយោជិតនៅក្នុងវិស័យកាត់ដេរ ស្បែកជើង និងវិស័យផលិតផ្សេងទៀត ។ ការបញ្ឈប់នាងពីរោងចក្រមួយរបស់ក្រុមហ៊ុនវ៉ាយធីស៊ី ដែលជាអ្នកផ្គត់ផ្គង់ផលិតផលដល់ក្រុមហ៊ុនមួយចំនួនដូចជា Gap, Old Navy និងWalmart គឺជាចេតនាយ៉ាងច្បាស់ក្នុងការកាត់បន្ថយសិទ្ធិកម្មករនៅជួរមុខ ។

ការបញ្ឈប់សុវណ្ណនីពីការងារបានកើតឡើង នៅពេលនាង និងកម្មករនិយោជិតជាច្រើននាក់ទៀតដែលត្រូវបានបញ្ឈប់ពីការងារ ជិតដល់ពេលទទួលបានកិច្ចសន្យាការងារមិនកំណត់ថេរវេលា ដែលផ្តល់សុវត្ថិភាពការងារ និងអត្ថប្រយោជន៍ល្អជាង កិច្ចសន្យាមានកំណត់ថេរវេលារបស់ពួកគេ ។

នាងបានលើកឡើងថា "ក្រុម [កម្មករដែលធ្វើការងារបាន] ពីរឆ្នាំចុះមកក្រោមហ្នឹង គឺគាត់មានហានិភ័យខ្លាំង ដោយសារតែខាងក្រុមហ៊ុន គាត់បញ្ចប់កិច្ចសន្យាដោយមិនគិតថា គាត់ជិតចូល UDC (កិច្ចសន្យាមិនកំណត់ថេរវេលា) អីទេ គឺក្រុមហ៊ុនបញ្ឈប់ឆៅៗហ្នឹង" ។ នាងបានបន្ថែមថា "បើតាមខ្ញុំគិតខ្លួនឯងប្រហែលជា ចេតនារបស់ក្រុមហ៊ុន ដោយសារតែខ្ញុំជាសកម្មជនសហជីពនៅក្នុងរោងចក្រហ្នឹង គឺសហជីពដែលឯករាជ្យ ជួយការពារសិទ្ធិនិងបញ្ហាប្រឈមរបស់បងប្អូនកម្មករ" ។

ការបញ្ឈប់ពីការងារបានធ្វើឱ្យសុវណ្ណនី មានការប្តេជ្ញាចិត្តកាន់តែខ្លាំង ដើម្បីទាមទារការគោរពសិទ្ធិកម្មករ ។ ខណៈដែលនាងរាយការណ៍ពីការធ្លាក់ចុះនៃប្រាក់ចំណូលរបស់នាង ចាប់តាំងពីបាត់បង់ការងារ នាងកំពុងចំណាយពេលច្រើនក្នុងការធ្វើការជាមួយសហព័ន្ធសហជីពកម្ពុជា ចងក្រងកម្មករ និងចែករំលែកចំណេះដឹងអំពីសិទ្ធិការងារ និងកិច្ចគាំពារសង្គម ជាដើម ។

សុវណ្ណនី ក៏តវ៉ាប្រឆាំងនឹងចៅហ្វាយនាយដែលមានលក្ខណៈរំលោភបំពាន ដែលឆ្លៀតយកតួនាទីរបស់ពួកគេ ដើម្បីប្រព្រឹត្តអំពើបៀតបៀនផ្លូវភេទ ជាមួយនឹងនិទណ្ឌភាព ។ នៅក្នុងករណីមួយ អ្នកគ្រប់គ្រងម្នាក់នៅក្នុងរោងចក្រវ៉ាយធីស៊ី បានបៀតបៀនផ្លូវភេទទៅលើកម្មការិនីជាច្រើនដង ហើយសហព័ន្ធសហជីព បានជួយកម្មការិនីទាំងនោះ ប្តឹងទៅនិយោជក និងក្រោយមកប្តឹងទៅស្ថាប័នពាក់ព័ន្ធដូចជា ក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងតាមរយៈប្រព័ន្ធច្បាប់ ។ ប៉ុន្តែសុវណ្ណនីថ្លែងដោយភាពមិនអស់ចិត្តថា ស្ថាប័នទាំងនេះ មិនបានជួយកម្មការិនីរងគ្រោះទេ ហើយអ្នកគ្រប់គ្រងនោះនៅតែកាន់ដំណែងការងារក្នុងរោងចក្រដដែល រហូតមកដល់សព្វថ្ងៃនេះ ។ នាងបាននិយាយថា "យើងកម្មករ អត់មានយុត្តិធម៌សម្រាប់យើង" ។

ប៉ុន្តែសុវណ្ណនី មិននៅស្ងៀមឡើយ ។ នាងទាមទារឱ្យអាជ្ញាធរបញ្ចប់រាល់ទម្រង់ទាំងអស់នៃការបៀតបៀន ហើយឱ្យនិយោជកគោរពសិទ្ធិសហជីព និងច្បាប់ ហើយស្នើឱ្យក្រុមហ៊ុនដូចជា Gap, Old Navy និងWalmart ឱ្យទទួលខុសត្រូវក្នុងការធានាថា កម្មករនិយោជិតមិនត្រូវបានបញ្ឈប់ពីការងារដោយអយុត្តិធម៌ ។ ចំពោះសកម្មជនសហជីពផ្សេងទៀត នាងសូមឱ្យពួកគេរួបរួមគ្នាក្នុងការតស៊ូ៖ "សូមបន្តធ្វើការនៅដំណាក់កាលទៅមុខ ដើម្បីជួយការពារសមាជិកយើងនៅក្នុងរោងចក្រហ្នឹង កុំឱ្យមានគេរំលោភបំពាន (សិទ្ធិកម្មករ និងសមាជិក)" ។

# សុខ ស្រីលាភ

## បុគ្គលិកយុទ្ធនាការនៃអង្គការបណ្ដាញការងារស្ត្រីរួបរួមគ្នា



អ្នកប្រកបរបរផ្លូវភេទ និងអ្នកធ្វើការផ្នែកសេវាកម្សាន្ត ប្រឈមនឹងលក្ខខណ្ឌការងារអសុវត្ថិភាព ។ ស្រីលាភ កំពុងតវ៉ាឱ្យមានការផ្លាស់ប្ដូរដើម្បីធានាថា អ្នកប្រកបរបរផ្លូវភេទ អាចធ្វើការដោយមានលក្ខខណ្ឌការងារសុវត្ថិភាព គ្មានការរើសអើង ការធ្វើទុក្ខបុកម្នេញ និងការរំលោភបំពាន ។

ស្រីលាភ ធ្វើការជាមួយបណ្ដាញការងារស្ត្រីរួបរួមគ្នា ជាអ្នកតំណាងឱ្យអ្នកប្រកបរបរផ្លូវភេទ និងអ្នកធ្វើការផ្នែកសេវាកម្សាន្ត ដែលតស៊ូមតិឱ្យមានការទទួលស្គាល់ការងារផ្លូវភេទជាការងារ ។ នាងដឹកនាំការតស៊ូមតិ និងសម្របសម្រួលការគាំទ្រសម្រាប់សមាជិក ជាពិសេសនៅពេលដែលពួកគេប្រឈមនឹងការរំលោភបំពាន ។

ជាទូទៅ អំពើហិង្សា ការធ្វើទុក្ខបុកម្នេញ និងការរើសអើង ប្រឆាំងនឹងអ្នកប្រកបរបរផ្លូវភេទ គឺប្រព្រឹត្តដោយអាជ្ញាធរ សមាជិកគ្រួសារ អតិថិជន អ្នកផ្ដល់សេវាសុខាភិបាល អ្នកជិតខាង និងផ្សេងទៀត ។ ស្រីលាភ បានរៀបរាប់ថា អំពើហិង្សាលើរូបរាងកាយ គឺកើតមានញឹកញាប់ ប៉ុន្តែជារឿយៗ សមាជិករបស់នាងក៏ប្រឈមនឹងអំពើហិង្សាផ្លូវភេទផងដែរ ដូចជាការរំលោភសេពសន្ថវៈបូកជាដើម ។ ស្រីលាភ បាននិយាយថា "ភ្ញៀវគិតថា អ្នកប្រកបរបរផ្លូវភេទអត់ហ៊ានប្ដឹង ព្រោះអីគាត់លក់សេវាផ្លូវភេទ ត្រូវរងការរើសអើង អ៊ីចឹង ផ្នត់គំនិតរបស់សង្គមគេគិតអ៊ីចឹង" ។

ទំនាក់ទំនងជាមួយអាជ្ញាធរ នៅពេលដែលការជួបជុំនៅតាមសហគមន៍ មានការរារាំងពីអាជ្ញាធរ ដោយមានការមកឈរស្ដាប់ដែលយើងមានការលំបាក ក្នុងការជជែកជាពិសេសទាក់ទងនឹងសុខភាពផ្លូវភេទរបស់ស្ត្រី ។ ទោះបីជាមានការធ្វើទុក្ខបុកម្នេញ និងការឃ្លាំមើលដោយអាជ្ញាធរជាបុរស ដែលជារឿយៗតែងតែរំខានដល់លទ្ធភាពក្នុងការតស៊ូមតិនៅមូលដ្ឋានរបស់បណ្ដាញការងារស្ត្រីរួបរួម អ្នកចងក្រងដូចស្រីលាភ នៅតែបន្តក្រោកឈរទាំងអស់គ្នា និងតស៊ូដើម្បីសិទ្ធិរបស់ពួកគេ ។

"សូមបញ្ឈប់ការដាក់ទោសទណ្ឌលើអ្នកប្រកបរបរផ្លូវភេទ និងការចាប់ខ្លួនអ្នកប្រកបរបរផ្លូវភេទ ព្រោះវាជាសិទ្ធិ ជាជម្រើស ជាការងារថ្លៃថ្នូររបស់អ្នកប្រកបរបរផ្លូវភេទ ជាសិទ្ធិជ្រើសរើសមុខរបរ សិទ្ធិប្រើប្រាស់រាងកាយ"

នៅពេលដែលអ្នកប្រកបរបរផ្លូវភេទទៅធ្វើការ ជាទូទៅគឺពុំមានសុវត្ថិភាពនោះទេ ពួកគាត់ តែងតែត្រូវបានឃាត់ខ្លួនជាញឹកញាប់ ដោយគ្រាន់តែមានវត្តមាននៅទីសាធារណៈ ឬការច្រឡំចោទប្រកាន់ថាជាចោរ ជាដើម ។ នាងបាននិយាយថា "គ្នាអង្គុយតែលើបង់ ក៏គេចាប់ដែរ អត់មានទៅពាក់ពួន ទៅបក់ដៃ ទាញអីក៏អត់ដែរ" ។

បណ្ដាញការងារស្ត្រីរួបរួមគ្នា ផ្ដល់សេវាគាំទ្រមួយចំនួន ដល់អ្នកធ្វើការផ្នែកសេវាកម្សាន្ត និងអ្នកប្រកបរបរផ្លូវភេទ ។ យើងមានប្រព័ន្ធទូរស័ព្ទ Hotline មួយខ្សែ សម្រាប់ករណីបន្ទាន់២៤ម៉ោងក្នុងមួយថ្ងៃ ការពង្រឹងភាពម្ចាស់ការនិងបណ្ដុះបណ្ដាលសមាជិកឱ្យចេះចងក្រងព័ត៌មាន ការដាក់ពាក្យបណ្ដឹងតាមច្បាប់ ក៏ដូចជាបង្កើតលំហសុវត្ថិភាព ដូចជាមណ្ឌលសំចត ដែលកម្មករនិយោជិតអាចចែករំលែកបទពិសោធន៍ និងការតស៊ូរបស់ពួកគេ ។ នាងបានលើកឡើងថា "មិនថាតែការចែករំលែកបទពិសោធន៍ទេ តែការចែករំលែកអ្វីដែលខ្លួនឯងមាន មិនថាការញ៉ាំការអីទេ ពួកយើងស្និទ្ធជាមួយគ្នាដូចគ្រួសារតែមួយចឹង" ។

ការរើសអើងដោយអ្នកផ្ដល់សេវាសុខភាព គឺជាបញ្ហាធ្ងន់ធ្ងរបំផុតមួយដែលប៉ះពាល់ដល់សមាជិក ។ អ្នកប្រកបរបរផ្លូវភេទដែលជាមនុស្សប្ដូរយេនឌ័រ និងបុរសដែលរួមភេទជាមួយបុរស ជាញឹកញាប់គឺត្រូវប្រឈមនឹងការរើសអើងឥតឈប់ឈរ ដែលធ្វើឱ្យពួកគេមានអារម្មណ៍ថា មិនមានសុវត្ថិភាពក្នុងការស្វែងរកសេវាសង្គ្រោះជីវិតទៀតទេ ។ នាងបាននិយាយថា "ជំងឺរបស់គេទៅជាធ្ងន់ធ្ងរ ដោយសារមិនបានព្យាបាលឱ្យបានត្រឹមត្រូវ" ។ សមាជិកមួយចំនួនដែលមានផ្ទុកមេរោគអេដស៍ ត្រូវបានដាច់ថ្នាំពន្យាជីវិតនៅក្នុងអំឡុងពេលបិទខ្ទប់។

ស្រីលាភ អំពាវនាវឱ្យរាជរដ្ឋាភិបាល បញ្ឈប់ការដាក់ទោសទណ្ឌលើអ្នកប្រកបរបរផ្លូវភេទ និងទទួលស្គាល់ការងារប្រកបរបរផ្លូវភេទគឺជាការងារ មានន័យថា រដ្ឋាភិបាលត្រូវលុបចោលនូវច្បាប់ដែលប៉ះពាល់ដល់សិទ្ធិអ្នកប្រកបរបរផ្លូវភេទ ក្នុងនោះរួមមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ដែលចែងពាក់ព័ន្ធនឹងអំពើអួសទាញនៅទីសាធារណៈ និងអំពើសព្វារកម្ម ជាបទប្បញ្ញត្តិដែលនាំឱ្យមានលក្ខខណ្ឌការងារអសុវត្ថិភាព និងដែលជាទូទៅរងការរំលោភបំពានដោយអាជ្ញាធរ ដោយការប្រព្រឹត្តិអំពើហិង្សា និងការចាប់ខ្លួនលើអ្នកប្រកបរបរផ្លូវភេទ ។ ស្រីលាភ អំពាវនាវឱ្យមានការធ្វើវិសោធនកម្មច្បាប់នេះ ដើម្បីការពារសិទ្ធិ និងសេរីភាពបុគ្គលរបស់អ្នកប្រកបរបរ ផ្លូវភេទឱ្យបានល្អប្រសើរ ។ ស្រីលាភ បាននិយាយថា "សូមបញ្ឈប់ការដាក់ទោសទណ្ឌលើអ្នកប្រកបរបរផ្លូវភេទ និងការចាប់ខ្លួនអ្នកប្រកបរបរផ្លូវភេទ ព្រោះវាជាសិទ្ធិ ជាជម្រើស ជាការងារថ្លៃថ្នូររបស់អ្នកប្រកបរបរផ្លូវភេទ ជាសិទ្ធិជ្រើសរើសមុខរបរ សិទ្ធិប្រើប្រាស់រាងកាយ" ។

បន្ថែមពីនេះ នាងបានស្នើសុំឲ្យរាជរដ្ឋាភិបាល ផ្តល់សេវាសាធារណៈពេញលេញ យុត្តិធម៌ មានគុណភាព និងឥតគិតថ្លៃសម្រាប់អ្នកប្រកបរបរផ្លូវភេទផងដែរ ។

សាររបស់ស្រីលាភចំពោះសាធារណជន គឺច្បាស់ៗថា "សូមឱ្យតម្លៃ (អ្នកប្រកបរបរផ្លូវភេទ) គាត់ក៏ជាមនុស្សដែរ ការងារអីក៏ជាការងារថ្លៃថ្នូរដែរ និងត្រូវទទួលបានសិទ្ធិមនុស្សទាំងអស់" ។

# ឃ្លាំង សុបិន្ត

## អគ្គលេខាធិការនៃសហជីពទ្រទ្រង់សិទ្ធិការងារ បុគ្គលិក កម្មករខ្មែរនៃក្រុមហ៊ុនណាហ្គាវើលដ៍



> "ពេលគាត់ចេញទៅតស៊ូមតិហ្នឹង ទទួលរងការប្រើប្រាស់ហិង្សា ពីសំណាក់អាជ្ញាធរដែលជាមនុស្សប្រុស វ៉ៃទាត់ធាក់គាត់ដែលជាមនុស្សស្រីហ្នឹង ប្រៀបដូចថាយើងមិនមែនជាមនុស្ស

អ្នកស្រី សុបិន្ត បានជាប់ពន្ធនាគារជាងពីរខែ ក្រោយពីអាជ្ញាធរឆ្មក់ចូលការិយាល័យសហជីពទ្រទ្រង់សិទ្ធិការងារ បុគ្គលិក កម្មករខ្មែរនៃក្រុមហ៊ុនណាហ្គាវើលដ៍ (សហជីពណាហ្គាវើលដ៍) ក្នុងខែធ្នូ ឆ្នាំ២០២១ ដោយបានចាប់ខ្លួនអ្នកស្រី និងថ្នាក់ដឹកនាំសហជីពផ្សេងទៀត ។ ប៉ុន្តែការចាប់ខ្លួនទាំងនេះ មិនអាចបញ្ឈប់ការតវ៉ាប្រចាំថ្ងៃរបស់សមាជិកសហជីពណាហ្គាវើលដ៍ ដែលកំពុងធ្វើកូដកម្មទាមទារឱ្យក្រុមហ៊ុនកាស៊ីណូណាហ្គាវើលដ៍ ទទួលយកកម្មករដែលត្រូវបានបញ្ឈប់ពីការងារ ឱ្យចូលធ្វើការវិញនោះទេ ។ ទោះបីជាអ្នកស្រី សុបិន្ត ត្រូវបានដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្នក្ដី បទចោទប្រឆាំងនឹងថ្នាក់ដឹកនាំ និងសមាជិកសហជីព ក៏ដូចជាសំណុំរឿងព្រហ្មទណ្ឌមិនសមហេតុផលថ្មីៗមួយចំនួនទៀត នៅតែកំពុងដំណើរការតាមផ្លូវតុលាការនៅឡើយ ។

អ្នកស្រី សុបិន្ត បានធ្វើការនៅកាស៊ីណូនេះអស់រយៈពេល ១៨ឆ្នាំមកហើយ រហូតដល់ពេលដែលអ្នកស្រី និងថ្នាក់ដឹកនាំសហជីពទាំងមូលត្រូវបានបញ្ឈប់ពីការងារក្នុងឆ្នាំ២០២១ ។ ទោះបីជាយ៉ាងណា អ្នកស្រី សុបិន្ត នៅតែរឹងមាំក្នុងការប្ដេជ្ញាចិត្ត ដើម្បីការពារសិទ្ធិរបស់កម្មករនិយោជិតនៅក្រុមហ៊ុនណាហ្គាវើលដ៍ ។

លក្ខខណ្ឌការងារកាន់តែអាក្រក់យ៉ាងឆាប់រហ័ស នៅពេលគ្មានសហជីពនៅក្នុងកាស៊ីណូ ដោយកម្មករនិយោជិតមួយចំនួនបានរាយការណ៍ពីការកាត់បន្ថយប្រាក់ឧបត្ថម្ភបន្ថែម និងប្រាក់ធ្វើការថ្ងៃឈប់សម្រាក ។ អ្នកស្រីបានរៀបរាប់ថា "ពួកគាត់បាត់បង់ច្រើនណាស់ អ្វីដែលសហជីពធ្លាប់ទាមទារពីមុន" ។ ដូចគ្នាផងដែរ សមាជិកសហជីពណាហ្គាវើលដ៍ដែលកំពុងតវ៉ានៅតាមដងផ្លូវ ត្រូវបានវាយដំ គំរាមកំហែង តាមដាន ចាប់ ឬឃាត់ខ្លួន និងបៀតបៀនផ្លូវភេទដោយអាជ្ញាធរជាបុរស ។ អ្នកស្រីបានលើកឡើងថា "ពេលគាត់ចេញទៅតស៊ូមតិហ្នឹង ទទួលរងការប្រើប្រាស់ហិង្សា ពីសំណាក់អាជ្ញាធរដែលជាមនុស្សប្រុស វ៉ៃទាត់ធាក់គាត់ដែលជាមនុស្សស្រីហ្នឹង ប្រៀបដូចថាយើងមិនមែនជាមនុស្ស" ។ ក្នុងករណីមួយ អំពើហិង្សាដោយអាជ្ញាធរបានធ្វើឱ្យស្ដ្រីមានផ្ទៃពោះម្នាក់រលូតកូន ។

អ្នកស្រី សុបិន្ត ក៏បានសម្ដែងភាពមិនអស់ចិត្តផងដែរ ។ ខណៈដែលរាជរដ្ឋាភិបាលអះអាងក្នុងការដឹកនាំកិច្ចខិតខំប្រឹងប្រែង ដើម្បីបញ្ចប់រាល់ទម្រង់ទាំងអស់នៃអំពើហិង្សាប្រឆាំងនឹងស្ដ្រីភេទ មន្ត្រីរបស់ខ្លួនបែរជាប្រព្រឹត្តអំពើហិង្សាទៅលើកូដករជាស្ដ្រី ទាំងកណ្ដាលថ្ងៃ ដោយគ្មានទោសទៅវិញ ។

អ្នកស្រី សុបិន្ត ក៏បានឃើញការបៀតបៀនផ្លូវភេទ និងអំពើហិង្សាផ្អែកលើយេនឌ័រនៅក្នុងកាស៊ីណូណាហ្គាវើលដ៍ ជាកន្លែងដែលភ្ញៀវជារឿយៗ បានប៉ះពាល់កម្មករនិយោជិត ឬបញ្ចេញកំហឹងនៅពេលចាញ់ល្បែង ខណៈដែលក្រុមហ៊ុនណាហ្គាវើលដ៍ បែរជាគាំទ្រខាងភ្ញៀវទៅវិញ ។ អ្នកស្រី បានរៀបរាប់ថា៖ "យើងបន្តស្នូរដេញដោលជំរុញក្រុមហ៊ុនរហូត បើនិយាយពីការស្នើសុំគឺយើងធ្វើជារឿយៗហ្នឹង ស្នើសុំឱ្យគិតពីសុខុមាលភាពរបស់បុគ្គលិក ជាពិសេសស្ដ្រីដែលគាត់ងាយរងគ្រោះខ្លាំង ព្រោះបុគ្គលិកជាស្ដ្រីនៅក្នុងក្រុមហ៊ុនគឺច្រើនជាងបុរស ហើយគាត់ប្រឈមនឹងភ្ញៀវច្រើនជាងបុគ្គលិកប្រុសៗប៉ុន្តែយើងអត់ដែលឃើញមានការឆ្លើយតបពីក្រុមហ៊ុនទេ"។

អ្នកស្រី ក៏បានយកឈ្នះសម្ពាធឱ្យចាកចេញពីថ្នាក់ដឹកនាំសហជីពផងដែរ ។ អ្នកស្រី បានលើកឡើងថា "គ្រួសារថា យើងជាស្ដ្រី ហេតុអីបានត្រូវខ្វាយខ្វល់រឿងសង្គម ការងារហ្នឹងជាការងាររបស់មនុស្សប្រុស យើងស្រីធ្វើតែការងារហើយមកផ្ទះ ធ្វើការងារផ្ទះយើង ដាំបាយធ្វើម្ហូបឱ្យប្ដី ម្ដាយឪពុក ឬកូន" ។ ជាង៨០%នៃសមាជិកសហជីពណាហ្គាវើលដ៍សរុបប្រមាណ២.០០០នាក់ គឺជាស្ដ្រី ប៉ុន្តែពួកគេនៅតែមិនត្រូវបានលើកទឹកចិត្តក្នុងការធ្វើការងារសំខាន់ៗ ។ អ្នកស្រីបន្ថែមថា "ប្រុសៗរួមការងារខ្លះវាយតម្លៃថា ការងារស្ដ្រីយើងមិនដល់គេអ៊ីចឹង ហេតុអីត្រូវចង់ធ្វើជាអ្នកដឹកនាំដែរ ខ្លួនយើងត្រឹមតែជាស្ដ្រីធ្វើជាជំនួយការគេទៅបានហើយ" ។

ទោះបីជាមានការធ្វើទុក្ខបុកម្នេញឥតឈប់ឈរ សហជីពណាហ្គាវើលដ៍ នៅតែមានជំហររឹងមាំជាមួយស្ដ្រីដូច អ្នកស្រី សុបិន្ត នៅក្នុងថ្នាក់ដឹកនាំ ។ អ្នកស្រី អំពាវនាវឱ្យអ្នកផ្សេងទៀតចូលរួម ទាមទារឱ្យក្រុមហ៊ុនណាហ្គាវើលដ៍ អនុញ្ញាតឱ្យមានសហជីពឯករាជ្យ និងការការពារសុខុមាលភាពរបស់បុគ្គលិក ក៏ដូចជាទាមទារឱ្យអាជ្ញាធរឈប់ការពារនិយោជកដែលមានលក្ខណៈកេងប្រវ័ញ្ច និងរំលោភបំពាន ។ អ្នកស្រី អំពាវនាវឱ្យអ្នកដទៃចូលរួមជាមួយគ្នាថា "សូមឱ្យបងៗបុគ្គលិកកម្មករទាំងអស់ គាត់ត្រូវហ៊ានប្រើប្រាស់សិទ្ធិមូលដ្ឋានរបស់ខ្លួនឯង ព្រោះយើងធ្វើការ យើងលក់តែកម្លាំងទេ យើងមិនបានលក់សេរីភាពរបស់យើងទេ ។

# អ៊ុក ឆាយ៉ារី

## ប្រធានសមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ



អ្នកស្រី ឆាយ៉ារី ត្រូវបានធាក់ដួលចេញពីម៉ូតូរបស់អ្នកស្រីយ៉ាងហិង្សា ក្រោយពីបានចូលសួរសុខទុក្ខសហជីព និងលោក រ៉ុង ឈុន ស្ថាបនិកសមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ នៅក្នុងពន្ធនាគារ ក្នុងឆ្នាំ២០២០ ។ អ្នកស្រី បានដឹងថា វាជាការវាយប្រហារដោយមានការគិតទុកជាមុន ។ គ្រូបង្រៀនអនុវិទ្យាល័យនៅក្នុងខេត្តកណ្តាលរូបនេះ ត្រូវបានបោះឆ្នោតឱ្យក្លាយជាប្រធានសមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យក្នុងឆ្នាំ២០១៦ និងបានប្រឈមនឹងការគំរាមកំហែងឥតឈប់ឈរ ចាប់តាំងពីចូលរួមនៅក្នុងសមាគម អស់រយៈពេលជាង២០ឆ្នាំមកនេះ ។

ក្នុងនាមជាប្រធានសមាគមគ្រូបង្រៀនឯករាជ្យធំជាងគេនៅកម្ពុជា អ្នកស្រី ឆាយ៉ារី ស្ថិតនៅជួរមុខគេប្រឆាំងនឹងការគំរាមកំហែងរបស់អាជ្ញាធរទៅលើគ្រូបង្រៀន ។ អ្នកស្រី សកម្មក្នុងការជំទាស់ទៅនឹងការគំរាមកំហែងរបស់អាជ្ញាធរ ការលុបឈ្មោះចេញពីក្របខ័ណ្ឌ និងសូម្បីតែការចាប់ដាក់ពន្ធនាគារនូវគ្រូបង្រៀន ដែលចូលរួមក្នុងសកម្មភាពសមាគម សម្តែងមតិដើម្បីសិទ្ធិការងារ ឬមានទំនាក់ទំនងជាមួយការរំលាយគណបក្សសង្គ្រោះជាតិ ដែលជាគណបក្សជំទាស់ ។

ទោះបីជាយ៉ាងនេះក្តី អ្នកស្រីបន្តព្យាយាម ខិតខំតស៊ូដើម្បីធានាថា សមាជិករបស់អ្នកស្រីចែករំលែកចំណេះដឹងរបស់ពួកគេនៅក្នុងសាលារៀន ដោយគ្មានការបៀតបៀនផ្លូវភេទ ការគំរាមកំហែង ឬការរើសអើង ដោយសារនយោបាយ ។ អ្នកស្រី បានចែករំលែកអំពីករណីមួយ ដែលសមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ ជោគជ័យក្នុងការគាំទ្របណ្តឹងមួយប្រឆាំងនឹងគោលការណ៍សាលារៀនមួយដែលបានបៀតបៀនផ្លូវភេទលើគ្រូបង្រៀនម្នាក់៖ "ខ្ញុំត្រូវតែមានភាពក្លាហានក្នុងការចូលរួម ជួយដល់ស្ត្រីជាពិសេសអ្នកគ្រូដែលគាត់កំពុងតែប្រឈមនឹងការរំលោភបំពាន ទាំងការបៀតបៀនកេរ្តិ៍ខ្មាសគាត់ដែរ។

"អ្វីដែលខ្ញុំសម្រេចចិត្តហើយ ទោះបីគំរាមកំហែងមួយពាន់មួយម៉ឺនដង ក៏ខ្ញុំមិនដែលរាថយដែរ ខ្ញុំស៊ូដល់ទីបញ្ចប់"

ខ្ញុំត្រូវតែក្លាហាន ដើម្បីរួមចំណែកគាំទ្រស្ត្រី ជាពិសេសគ្រូបង្រៀនជាស្ត្រី ដែលប្រឈមនឹងការរំលោភបំពាន រួមទាំងការបៀតបៀនផ្លូវភេទផងដែរ" ។ អ្នកស្រីបន្ថែមថា "ការស្រម៉ៃរបស់ខ្ញុំគឺ ចង់ឱ្យលោកគ្រូអ្នកគ្រូហ្នឹង ទទួលបានការរស់រានមានជីវិត ហើយសេចក្តីថ្លៃថ្នូរ ប្រាក់បៀវត្សគ្រប់គ្រាន់ សមល្មមនឹងផ្ទេរចំណេះដឹងឱ្យសិស្សានុសិស្ស ដើម្បីឱ្យគាត់ទទួលបាននូវការអប់រំសម្រាប់ទាំងអស់គ្នា អត់មានការភ័យខ្លាច អត់មានការគំរាមកំហែង" ។

អ្នកស្រី ឆាយ៉ារី បានមើលឃើញពីតម្រូវការជាចម្បងនៃវត្តមានស្ត្រីជាច្រើនទៀតនៅជួរមុខនៃភាពសកម្មនិយម ក៏ដូចជាសារៈសំខាន់នៃការគាំទ្រ ជាពិសេសពីស្វាមី ក្នុងការធានាថា ស្ត្រីអាចក្រោកឈរឡើងដើម្បីសិទ្ធិរបស់ពួកគេ ។ ខណៈដែលគ្រូបង្រៀនជាងពាក់កណ្តាលនៃគ្រូបង្រៀនទាំងអស់នៅកម្ពុជាគឺជាស្ត្រី អ្នកស្រីលើកឡើងថា សមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យមានសមាជិកជាស្ត្រីប្រមាណជា ៣០% ក្នុងចំណោមសមាជិកទាំងអស់ជាងមួយម៉ឺននាក់ ។ អ្នកស្រីរៀបរាប់ថា "គ្រួសាររបស់គាត់បិទសិទ្ធិសេរីភាព ប្តីគាត់ថាកុំ ដោយសារតែឃើញការដើរហើរ ខ្លាចអត់មានសុវត្ថិភាពសម្រាប់គាត់ អត់មានអ្នកណាដាំបាយសម្លឱ្យគាត់ អ៊ីចឹងទៅ អត់មានអ្នកណាមើលកូនមើលចៅរបស់គាត់ ចឹងនេះហើយជាបញ្ហាដែលធ្វើឱ្យស្ត្រីភាគតិចណាស់ក្នុងការលះបង់ក្នុងការចូលរួម"។

អ្នកស្រី ឆាយ៉ារី ត្រូវបានឃ្លាំមើលដោយអាជ្ញាធរ ដែលរង់ចាំនៅក្រៅផ្ទះរបស់អ្នកស្រី និងតាមដានអ្នកស្រី ។ អ្នកស្រី ធ្លាប់ទទួលរងការគំរាមកំហែងដល់អាយុជីវិត ឬស្នើឱ្យទទួលយកប្រាក់សំណូកដើម្បីបញ្ឈប់ភាពសកម្មនិយមរបស់អ្នកស្រី ហើយកូនស្រីរបស់អ្នកស្រី ត្រូវបានបៀតបៀនផ្លូវភេទដោយអាជ្ញាធរ អំឡុងពេលចូលរួមការតវ៉ាឱ្យដោះលែងសកម្មជនដែលជាប់ឃុំដោយអយុត្តិធម៌ ។ ប៉ុន្តែអ្នកស្រីនៅតែរឹងមាំ៖ "អ្វីដែលខ្ញុំសម្រេចចិត្តហើយ ទោះបីគំរាមកំហែងមួយពាន់មួយម៉ឺនដង ក៏ខ្ញុំមិនដែលរាថយដែរ ខ្ញុំស៊ូដល់ទីបញ្ចប់" ។

អ្នកស្រីបន្តការតស៊ូដើម្បីទាមទារឱ្យរាជរដ្ឋាភិបាលអនុញ្ញាតឱ្យមានការពិភាក្សារឿងនយោបាយនៅក្នុងសាលារៀន ។ អ្នកស្រីអំពាវនាវឱ្យគ្រូបង្រៀនទាំងអស់ក្លាហាននិយាយចេញ៖ "យើងត្រូវតែហ៊ានក្នុងការចូលរួមដើម្បីស្តារប្រទេសជាតិយើងឱ្យមានលទ្ធិប្រជាធិបតេយ្យដ៏ពិតប្រាកដ" ។

# សុវណ្ណ វ៉ារី

## ប្រធានគណៈកម្មការស្ត្រីនៃសមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ




ដើម្បីកុំឱ្យភ្ញៀវបៀតបៀនទៀត អ្នកស្រី វ៉ារី បានដំឡើងរបារដែកនៅចន្លោះកៅអីអ្នកបើកបរ និងកៅអីភ្ញៀវ នៅក្នុងរ៉ឺម៉កកង់បីរបស់អ្នកស្រី ។ ក្នុងនាមជាអ្នកបើកបរជាស្ត្រីនៅក្នុងវិស័យដែលភាគច្រើនជាមនុស្សប្រុស អ្នកស្រី វ៉ារី បានជំនះនូវបញ្ហាប្រឈម ដើម្បីអភិវឌ្ឍខ្លួនក្លាយជាថ្នាក់ដឹកនាំមួយរូបនៅក្នុងសមាគមអ្នកស្រី ។

បន្ទាប់ពីក្លាយជាអ្នកបើកបររ៉ឺម៉កកង់បីក្នុងឆ្នាំ២០១៨ អ្នកស្រី វ៉ារី បានចូលរួមជាមួយសមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (សមាគម IDEA) ជាសមាគមកម្មករមួយ ដែលធ្វើការជាមួយអ្នកបើកបររ៉ឺម៉កកង់បី អ្នកលក់ដូរតាមដងផ្លូវ អ្នករើសអេតចាយ ឬអ្នករើសសម្រាម និងអ្នកផ្សេងទៀត ។ ដំបូង អ្នកស្រីចូលរួមជាមួយសមាគម IDEA ដោយសារភាពចាំបាច់ និងការជួបប្រឈមនឹងហានិភ័យដោយសារការធ្វើការនៅតាមដងផ្លូវ ។ អ្នកស្រី បានលើកឡើងថា "នៅពេលដែលបងប្អូន ឬក៏ខ្ញុំមានបញ្ហាប្រឈម ដូចជាគ្រោះថ្នាក់ចរាចរណ៍ គឺពិបាកមែនទែនហ្មង គ្មានរដ្ឋ ឬគ្មានAppណា ក្រុមហ៊ុនណា មកជួយយើងទេ" ។

តាំងពីពេលនោះមក អ្នកស្រី វ៉ារី បានក្លាយជាប្រភពគាំទ្រដ៏សំខាន់មួយ សម្រាប់សមាជិកដទៃទៀតដែលធ្វើការនៅក្នុងខណ្ឌចំការមន ក្នុងរាជធានីភ្នំពេញ ។ អ្នកស្រីតែងតែសម្របសម្រួលការជួយគាំទ្រ មិនថាពេលមានរ៉ឺម៉កកង់បីខូច ឬពាក់ព័ន្ធនឹងគ្រោះថ្នាក់ចរាចរណ៍ ឬអ្នកលក់ដូរតាមដងផ្លូវគឺត្រូវបានអាជ្ញាធរបង្ខំឱ្យចាកចេញ ឬអ្នកបើកបរត្រូវបានបៀតបៀនផ្លូវភេទដោយភ្ញៀវ ជាដើម ។

ការប្តេជ្ញាចិត្តរបស់អ្នកស្រី មិនបានការពារអ្នកស្រីពីការរើសអើងនោះទេ ជាពិសេសពីសំណាក់អ្នកបើករ៉ឺម៉កកង់បីជាបុរស ដែលគិតថាស្ត្រីមិនគួរធ្វើការលើវិស័យនេះ ។ អ្នកស្រី វ៉ារី បានលើកឡើងថា ប្រមាណជា១៦%នៃសមាជិកសមាគមIDEA សរុបចំនួន ១៨.០០០ នាក់គឺជាស្ត្រី ប៉ុន្តែនៅតែមានវិសមភាពយេនឌ័រនៅក្នុងវិស័យនីមួយៗ ។ អ្នកស្រីបានរៀបរាប់ថា "បើជាស្ត្រីវិញ ខ្ញុំចង់ឱ្យស្ត្រីហ្នឹងទទួលបានការគាំទ្រពីមជ្ឈដ្ឋានមនុស្សនៅក្នុងសង្គម ឱ្យតម្លៃគាត់ ព្រោះអីនៅពេលគេឃើញស្ត្រីរត់កង់បី គឺគេអត់ឱ្យតម្លៃហ្នឹងហ្មង" ។

"នៅពេលដែលបងប្អូន ឬក៏ខ្ញុំមានបញ្ហាប្រឈម ដូចជាគ្រោះថ្នាក់ចរាចរណ៍ គឺពិបាកមែនទែនហ្មង គ្មានរដ្ឋ ឬគ្មានAppណា ក្រុមហ៊ុនណា មកជួយយើងទេ"

បញ្ហាប្រឈមធំជាងគេមួយរបស់អ្នកស្រី វ៉ារី គឺការរំលោភបំពានពីសំណាក់ភ្ញៀវ ជាពិសេសនៅពេលយប់ ។ អ្នកស្រី បានប្រឈមនឹងសំណើផ្លូវភេទ និងការប៉ះពាល់ខ្លួនប្រាណ ដែលអ្នកស្រីមិនចូលចិត្តពីសំណាក់ភ្ញៀវ ដែលជារឿយៗតែងស្នើឱ្យស្ត្រីបើករ៉ឺម៉កកង់បីបើកទៅផ្លូវស្ងាត់ ឬបង្ខំឱ្យពួកគាត់បើកជុំវិញឥតឈប់ឈរ ។ សាមគ្គីភាពជាមួយស្ត្រីអ្នកបើករ៉ឺម៉កកង់បីដទៃទៀត បានផ្តល់ឱ្យ អ្នកស្រី វ៉ារី នូវភាពរឹងមាំ ដោយអ្នកស្រីគ្រប់គ្រងក្រុមថេឡេក្រាមមួយដែលរួមបញ្ចូលស្ត្រីអ្នកបើករ៉ឺម៉កកង់បីដើម្បីបង្កើនសុវត្ថិភាពរបស់ពួកគេ និងអនុញ្ញាតឱ្យសមាជិកផ្តល់ការគាំទ្រ និងផ្តល់យោបល់ឱ្យគ្នាទៅវិញទៅមក ក្នុងពេលធ្វើការ" ។

ក្រៅពីការងារ និងតួនាទីជាថ្នាក់ដឹកនាំ អ្នកស្រី វ៉ារី កំពុងចិញ្ចឹមបីបាច់កូនស្រីអាយុ ១១ឆ្នាំម្នាក់ ។ ក្នុងនាមជាម្តាយដែលចិញ្ចឹមកូនម្នាក់ឯង កូនរបស់អ្នកស្រី តែងតែជិះរ៉ឺម៉កកង់បីជាមួយអ្នកស្រី ក្នុងពេលអ្នកស្រីធ្វើការ ។ ដោយសារតែគ្មានដំណោះស្រាយងាយស្រួលផ្សេងទៀត អ្នកស្រីមានអារម្មណ៍ការធ្វើបែបនេះគឺមានសុវត្ថិភាពជាងការដែលទុកកូនស្រី នៅក្នុងបន្ទប់ជួលម្នាក់ឯង ។

សព្វថ្ងៃនេះ កម្មករសេដ្ឋកិច្ចក្រៅប្រព័ន្ធ ពិបាកក្នុងការទទួលបាន បេឡាជាតិរបបសន្តិសុខសង្គម ដោយបានផាត់ពួកគេចេញពីកិច្ចការពារសង្គមជាមូលដ្ឋានមួយចំនួនដូចជា ការធានារ៉ាប់រងសុខភាព ការគាំទ្រក្នុងករណីមានរបួស ឬគ្រោះថ្នាក់ការងារ និងប្រាក់សោធននិវត្តន៍ ជាដើម ។ អ្នកស្រី វ៉ារី អំពាវនាវឱ្យរដ្ឋាភិបាល ជួយផ្តល់ការការពារពេញលេញ ចំពោះកម្មករសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដោយសារតែក្រុមហ៊ុនឬកម្មវិធីជិះរ៉ឺម៉ក មិនបានផ្តល់កិច្ចការពារឬការគាំទ្រដល់ពួកគាត់ទេ ទោះបីជាពួកគេទទួលបានកម្រៃជើងសារច្រើនយ៉ាងណាក៏ដោយ ។ អ្នកស្រី វ៉ារី អំពាវនាវឱ្យកម្មការិនីផ្សេងទៀត ចូលរួមតស៊ូជាមួយអ្នកស្រី៖ "ខ្ញុំចង់]ឱ្យគាត់បានមានមតិ ក្នុងការក្រោកឈរ ទទួលនិងទាមទារសិទ្ធិដែលគាត់ត្រូវតែក្លាហានឡើង ចំពោះឧបសគ្គទាំងអស់" ។

# ម៉ាក់ កាក់

## សមាជិកនៃសមាគមអ្នកធ្វើការងារតាមផ្ទះ



អ្នកស្រី កាក់ ចាប់ផ្តើមធ្វើការងារដំបូង ជាអ្នកធ្វើការងារតាមផ្ទះ បន្ទាប់ពីបានផ្លាស់ប្តូរទីលំនៅពីខេត្តតាកែវ មករាជធានីភ្នំពេញ ប្រមាណជា ៩ឆ្នាំមុន ។ អ្នកស្រី បានលើកឡើងពីម្ចាស់ផ្ទះម្នាក់ថា "គេស្តីបន្ទោសយើងរៀងរាល់ថ្ងៃ ។ វាជាអំពើហិង្សាផ្លូវចិត្ត" ។

បន្តិចក្រោយមក អ្នកស្រី កាក់ បានផ្លាស់ប្តូរការងារទៅក្រុមហ៊ុនមួយទៀត ដែលបានផ្តល់លក្ខខណ្ឌការងារប្រសើរជាងមុន ហើយនៅរយៈពេលប្រមាណជា ៣ឆ្នាំមុន អ្នកស្រី បានចូលរួមជាមួយសមាគមអ្នកធ្វើការងារតាមផ្ទះ ជាសមាគមមួយដែលតំណាងឱ្យអ្នកធ្វើការងារតាមផ្ទះនៅក្នុងប្រទេសកម្ពុជា និងនៅក្រៅប្រទេស ។ ក្រោយពីមានអារម្មណ៍ថាមានទំនុកចិត្តច្រើនក្នុងការឆ្លើយតបនឹងការរំលោភសិទ្ធិ អ្នកស្រី កាក់ បានចាប់ផ្តើមសម្តែងមតិដើម្បីឱ្យមានកិច្ចការពារប្រសើរជាងមុនសម្រាប់អ្នកធ្វើការងារតាមផ្ទះទាំងអស់ ។

អ្នកស្រីបានចែករំលែក និងកត់សម្គាល់ថា សមាជិកខ្លះគ្មានជម្រើសអ្វីផ្សេងក្រៅពីធ្វើការរហូតដល់ ១៣ម៉ោងក្នុងមួយថ្ងៃ ដោយគ្មានថ្ងៃចុងសប្តាហ៍ ឬថ្ងៃឈប់សម្រាក "ធ្វើការងារនៅក្នុងតាមផ្ទះថៅកែមួយៗហ្នឹង ការពិតទៅមានប្រឈមមុខនឹងបញ្ហាអំពើហិង្សាផ្លូវចិត្ត អំពើហិង្សាផ្លូវកាយខ្លះៗ ធ្វើការហួសកម្លាំង ដូចថាធ្វើការច្រើនម៉ោងអ៊ីចឹង" ។

អ្នកធ្វើការងារតាមផ្ទះ ត្រូវបានផាត់ចេញស្ទើរតែទាំងអស់ពីកិច្ចការពារដែលមានចែងនៅក្នុងច្បាប់ស្តីពីការងារ ហើយមានមនុស្សតិចតួចប៉ុណ្ណោះដែលទទួលបានកិច្ចការពារតាមបេឡាជាតិរបបសន្តិសុខសង្គម ។

"ធ្វើការងារនៅក្នុងតាមផ្ទះថៅកែមួយៗហ្នឹង ការពិតទៅមានប្រឈមមុខនឹងបញ្ហាអំពើហិង្សាផ្លូវចិត្ត អំពើហិង្សាផ្លូវកាយខ្លះៗ ធ្វើការហួសកម្លាំង ដូចថាធ្វើការច្រើនម៉ោងអ៊ីចឹង"

ហានិភ័យដែលបង្កឡើងដោយថៅហ្វាយនាយ ឬលក្ខខណ្ឌការងារបែបកេងប្រវ័ញ្ច គឺមានភាពធ្ងន់ធ្ងរសម្រាប់អ្នកធ្វើការងារតាមផ្ទះដូចអ្នកស្រី កាក់ ដោយសារពួកគាត់ជាច្រើនត្រូវរស់នៅកន្លែងធ្វើការតែម្តង ។ អ្នកស្រី កត់សម្គាល់ថា តួនាទីយ៉ាងសំខាន់របស់សមាគមអ្នកធ្វើការងារតាមផ្ទះសម្រាប់អ្នកធ្វើការងារតាមផ្ទះ នៅពេលដែលពួកគេប្រឈមនឹងអំពើហិង្សានៅកន្លែងការងារ ។ អ្នកស្រី បាននិយាយថា "យើងអត់អាចឆ្លើយតបជាមួយនិយោជកបានទេ ដោយសារយើងទន់ខ្សោយ យើងអត់អាចតវ៉ាជាមួយគាត់បានទេ អ៊ីចឹងមានតែពឹងទៅខាងសមាគមគាត់ជួយដោះស្រាយឱ្យយើង" ។ ដោយសារសមាជិកសមាគមអ្នកធ្វើការងារតាមផ្ទះ ជាប់ធ្វើការនៅកន្លែងការងារខុសៗគ្នា និងមិនអាចជួបគ្នាដោយផ្ទាល់បាន បណ្តាញសង្គមបានក្លាយជាមធ្យោបាយសំខាន់ក្នុងការរៀបចំ និងសម្របសម្រួលការជួយគាំទ្រ ។

ក្នុងនាមជាស្ត្រីមេម៉ាយដែលមានកូនបីនាក់ បញ្ហាប្រឈមខ្លាំងជាងគេរបស់អ្នកស្រី កាក់ គឺការរកប្រាក់ចំណូលឱ្យបានគ្រប់គ្រាន់ ដើម្បីផ្គត់ផ្គង់គ្រួសារ ។ អ្នកស្រី អំពាវនាវឱ្យថៅកែទាំងអស់ទទួលស្គាល់តម្លៃ និងតម្រូវការរបស់អ្នកធ្វើការងារតាមផ្ទះ ដោយការផ្តល់ប្រាក់ឈ្នួលសមរម្យ ។

អ្នកស្រី កាក់ ទាមទារឱ្យមានការការពារជាក់លាក់ដោយច្បាប់ចំពោះអ្នកធ្វើការងារតាមផ្ទះ ដូចអ្វីដែលកម្មករនិយោជិតផ្សេងទៀតទទួលបាន ។ អ្នកស្រី ក៏ស្នើឱ្យថៅកែបញ្ចប់ការប្រើប្រាស់អំពើហិង្សា "ខ្ញុំសំណូមពរឱ្យថៅកែទាំងអស់ ឱ្យបញ្ឈប់អំពើហិង្សាលើកម្មករដែលធ្វើការងារតាមផ្ទះ ដូចជាអំពើហិង្សាផ្លូវចិត្ត អំពើហិង្សាផ្លូវភេទ អំពើហិង្សាផ្លូវកាយ" ៕




កូដករសហជីពណាហ្គាវើលដ៏ម្នាក់ អំពាវនាវឱ្យបញ្ឈប់ការរើសអើងលើបុគ្គលិកកម្មករជាស្ត្រី
នៅក្នុងការតវ៉ាមួយ ក្នុងរាជធានីភ្នំពេញ កាលពីខែសីហា ឆ្នាំ២០២២ ។

www.licadho-cambodia.org